ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**នាមនាមប្រជារាស្ត្រខ្មែរ**

សំណុំរឿងរដ្ឋប្បវេណី **សាលាឧទ្ធរណ៍ភ្នំពេញ**

លេខៈ ១៩១/០៤.៦.២០១៣ បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នាថ្ងៃទី២៦.៩.២០១៣

សាលដីកា **ក្រុមប្រឹក្សាជំនុំជំរះ**

លេខៈ ២៦ក្រIVអ/០១.១០.២០១៣ លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រម

លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

-ដើមចោទ ឈ្មោះ [redacted] ហេងហួរ ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ០៨E₁ ផ្លូវលេខ៥១៤ ក្រុម១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-ចុងចម្លើយ ឈ្មោះ [redacted] ណុប ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៨៥ ផ្លូវលេខ១០១៩ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

-មេធាវី លោក [redacted] តំណាងដោយអាណត្តិអោយចុងចម្លើយ ។

**កម្មវត្ថុបណ្តឹង ៖**

-ទាមទារប្រាក់ចំនួន១១,០៩៥$ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លារអាមេរិក)

-ការប្រាក់តាមច្បាប់

-សំណងជម្ងឺចិត្តចំនួន៣,០០០$ (បីពាន់ដុល្លាអាមេរិក) ។

**អង្គហេតុ និងចំណុចវិវាទ ៖**

កាលពីថ្ងៃទី ២០.០២.២០០៩ ឈ្មោះ [redacted] ហេងហួរ បានទទួលម៉ៅការសាងសង់ផ្ទះ២ល្វែង តម្លៃ ៣០,០០០$ អោយទៅឈ្មោះ [redacted] ណុប និងប្រពន្ធដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ដោយនៅក្នុងកិច្ចសន្យា មានការបែងចែកជា០៦ដំណាក់កាល ក្នុងមួយដំណាក់កាលឈ្មោះ [redacted] ណុប និងប្រពន្ធត្រូវទូទាត់ប្រាក់អោយឈ្មោះ [redacted] ហេងហួរ ចំនួន ៥០០០$ នៅពេលកំពុងសាងសង់ឈ្មោះ [redacted] ណុប និងប្រពន្ធ ទូទាត់ប្រាក់អោយឈ្មោះ [redacted] ហេងហួរ មិនទាន់គ្រប់ទេ នៅខ្វះចំនួន ១១០៩៥$ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) ទៀត ពុំព្រមទូទាត់ ដោយឈ្មោះ [redacted]

១១៥

Scanned with CamScanner

ណុប និងប្រពន្ធចេះតែប្រកែកថា បានទូទាត់អោយរួចរាល់អស់ហើយ តែធាតុពិតគាត់ពុំទាន់បានទូទាត់អោយនោះទេ ។

ការអះអាងរបស់គូភាគី

-ដើមចោទ ឈ្មោះ [redacted] ហេងហួរ ធ្វើសេចក្តីថ្លែងហេតុថា ៖ ចុងចម្លើយឈ្មោះ [redacted] ណុប និងប្រពន្ធឈ្មោះ [redacted] សុខណារី នៅជំពាក់ប្រាក់ខ្ញុំ ចំនួន ១១០៩៥$ ។ ឈ្មោះ [redacted] ណុប បានសងប្រាក់នាងខ្ញុំ បានតែជំហានទី១ នៅថ្ងៃទី ២០.២.២០០៩ ជំហានទី២ នៅថ្ងៃ ១១.៣.២០០៩ ជំហានទី៣ នៅថ្ងៃ ២៥.៣.២០០៩ ជំហានទី៤ នៅថ្ងៃ ១២.៤.២០០៩ សរុបទាំង ៤លើក បានចំនួន ២០០០០ដុល្លាអាមេរិក ដោយមានស្នាមមេដៃប្រគល់ និងទទួលត្រឹមត្រូវ ។ នាងខ្ញុំមិនទាន់បានទទួលប្រាក់ជំពាក់ជំហានទី៥ និងទី៦ សរុប ១០០០០$ (មួយម៉ឺន)ដុល្លាអាមេរិក ពីឈ្មោះ [redacted] ណុប និងប្រពន្ធគាត់ទេ ។ ប្រាក់នេះ គឺប្រាក់បិតការ៉ូបាត , ការ៉ូជញ្ជាំង និងដាក់គ្រឿងទារកញ្ចក់ ខ្សែភ្លើង និងគ្រឿងបំពាក់ផ្សេងៗទៀត ។ ចំពោះចុងចម្លើយថា បានសងប្រាក់ខ្ញុំនៅជំហានទី៥ និងទី៦ សរុបចំនួន ១០០០០$ (មួយម៉ឺន)ដុល្លាអាមេរិកនោះ នាងខ្ញុំមិនបានទទួលប្រាក់នោះទេ ហើយនាងខ្ញុំក៏មិនបានគូសលើក្រដាសជំពាក់នោះដែរ គឺចុងចម្លើយជាអ្នកគូសតែម្នាក់ឯង នាងខ្ញុំសុំប្តឹងពីឈ្មោះ [redacted] ណុប និងប្រពន្ធ ដែលបានបន្លំលើឯកសារជំពាក់ប្រាក់នេះ ។

សំណូមពរ ៖ សូមលោកតុលាការតម្កល់សាលក្រមរដ្ឋប្បវេណី លេខ ៧៤ "ធ" ចុះថ្ងៃទី ០៤.១២.២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកនៅដដែល ព្រោះថា ប្រាក់ដែលសាលាដំបូងកាត់អោយសងលើប្រាក់ខាតបង់ផ្សេងៗ ចំនួន ៥០០០$ នោះ គឺចុងចម្លើយបានដឹកយកក្តាពុម្ព ចំនួន ១២ម៉ែត្រគូប និងកូនឈើចំនួន ៥០០ដើម ជារបស់នាងខ្ញុំយកទៅអស់ ។

-ចុងចម្លើយ ឈ្មោះ [redacted] សុខណារី បានធ្វើសេចក្តីថ្លែងហេតុថា ៖ ចំពោះប្រាក់ជំពាក់ នាងខ្ញុំបានសងអោយដើមចោទគ្រប់ចំនួន ដោយមានកិច្ចសន្យា លិខិតប្រគល់ប្រាក់ ព្រោះគាត់បើកលុយគាត់យកក្រដាសអោយខ្ញុំសសេរ ចំពោះអក្សរជាអក្សរប្តីខ្ញុំ ខ្ញុំជាអ្នកអោយលុយគាត់ ។ ចំពោះកិច្ចសន្យាម៉ៅការ គឺប្តីគាត់អ្នកយកមកអោយខ្ញុំ ។ ខ្ញុំបានសងគាត់លើកទី១ ៥០០០$ លើកទី២ ៥០០០$ លើកទី៣ ៥០០០$ និងលើកទី៤ ៥០០០$ ចុងក្រោយលើកទី៥ ៥០០០$ និងលើកទី៦ ៥០០០$ គឺគាត់បានគូសនៅក្នុងឯកសារកំណត់ដៃរបស់ខ្ញុំ ។

សំណូមពរ ៖ សូមលោកតុលាការ សម្រេចអោយនាងខ្ញុំបានរួចផុតពីបំណុល ។

-មេធាវី លោក [redacted] តំណាងអោយអាណត្តិអោយចុងចម្លើយ ធ្វើសេចក្តីថ្លែងហេតុថា ៖ ក្នុងរឿងនេះ កូនក្តីខ្ញុំឈ្មោះ [redacted] ណុប និងប្រពន្ធឈ្មោះ [redacted] សុខណារី បានប្តឹងឧទ្ធរណ៍ មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណី លេខ ៧៤ "ធ" ចុះថ្ងៃទី ៤.១២.២០១២ ត្រង់ចំណុចទាំងមូល ដោយសាលក្រមនេះ សម្រេចមានភាពអយុត្តិធម៌មកលើកូនក្តីខ្ញុំ ព្រោះកូនក្តីខ្ញុំបានប្រគល់ប្រាក់សងរួចអស់ហើយ គឺប្រគល់អោយឈ្មោះ [redacted] រី កូនក្តីខ្ញុំទទួលស្គាល់ថា នៅជំពាក់តែប្រាក់ ចំនួន ១០៩៥$ ប៉ុណ្ណោះ គឺមានកំណត់ចំណាំរបស់គាត់ គឺគូសខ្វែងនៅលើចំនួនទឹកប្រាក់ ៥០០០ដុល្លាតាមជំហាននីមួយៗ នៃការសាងសង់ រហូតដល់ជំហានទី៦ សរុប ៣០០០០ដុល្លា កូនក្តីខ្ញុំបានប្តឹងទៅសាលាខណ្ឌសែនសុខ ហើយដើមចោទឈ្មោះ [redacted] ហេងហួរ ក៏បានទទួលស្គាល់ថា បានសងចំនួន ៣០០០០ដុល្លាអាមេរិកដែរ ។



Scanned with CamScanner

សំណូមពរ ៖ សុំប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សា ច្រានចោលសាលក្រមរដ្ឋប្បវេណី លេខ ៧៤ "ធ" ចុះថ្ងៃ ៤.១២.២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ និងសូមសម្រេចអោយកូនក្តីខ្ញុំ រួចផុតពីបំណុល ។

## សំអាងហេតុ

-យល់ឃើញថា ៖

១.បណ្តឹងឧទ្ធរណ៍ លេខ ៦៦ ចុះថ្ងៃ ៦ មីនា ២០១៣ របស់ឈ្មោះ [redacted] ណុប ជាចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ សាលាឧទ្ធរណ៍ ទទួលជំនុំជំរះបាន ។

- មេធាវី [redacted] តំណាងដោយអាណត្តិអោយចុងចម្លើយ ។

២.មេធាវីតំណាងអោយចុងចម្លើយ ឈ្មោះ [redacted] ណុប បានថ្លែងហេតុថា ឈ្មោះ [redacted] ណុប និងប្រពន្ធឈ្មោះ [redacted] សុខណារី បានម៉ៅការសាងសង់ផ្ទះល្វែង ២ល្វែងជាន់$E_0$ អោយទៅឈ្មោះ [redacted] ហេងហួរ និងប្តីឈ្មោះ [redacted] វី ក្នុងតម្លៃ ៣០០០០(បីម៉ឺន)ដុល្លាអាមេរិក ។

តាមកិច្ចសន្យាសង់ផ្ទះ (ឯ.១/៧) បញ្ជាក់ថា ការសាងសង់ចាប់ផ្តើមនៅថ្ងៃ ១៩ កុម្ភៈ ២០០៩ ដោយភាគីម្ចាស់សំណង់សន្យាផ្តល់ប្រាក់ទៅអោយភាគីម៉ៅការ ទៅតាមជំហានទី១ ដល់ទី៦ ។ ក្នុងមួយជំហានៗ ចំនួន ៥០០០ដុល្លាអាមេរិក ។ភាគីសាងសង់ ឈ្មោះ [redacted] ហេងហួរ ជាអ្នកទទួលទិញ និងផ្គត់ផ្គង់សំភារៈសំណង់ ដោយទទួលប្រាក់ពីម្ចាស់សំណង់ ឈ្មោះ [redacted] ណុប ។ ឯឈ្មោះ [redacted] វី ជាប្តីជាអ្នកឈរមើលការសាងសង់ ។

ក្នុងការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា ឈ្មោះ [redacted] ណុប ឆ្លើយថា ខ្លួនពុំទទួលស្គាល់ប្រាក់ជំពាក់ ដែលដើមចោទទាមទារចំនួន ១១០៨៥ដុល្លានោះទេ ។ ខ្លួនបានប្រគល់សងរួចអស់ហើយ គឺប្រគល់អោយឈ្មោះ [redacted] វី ។ ខ្លួនទទួលស្គាល់ថា នៅជំពាក់តែ ១០៨៥ដុល្លាប៉ុណ្ណោះ (ឯ.១៣) ដូចមានកំណត់ចំណាំរបស់ខ្លួនលើកិច្ចសន្យាសង់ផ្ទះ គឺគូសខ្វែងនៅលើចំនួនទឹកប្រាក់ ៥០០០ដុល្លា តាមជំហានៗ នៃការសាងសង់រហូតដល់ជំហានទី៦ សរុប ៣០០០០ដុល្លា ។ ដូចនេះ ថ្លៃម៉ៅការសាងសង់ចំនួន ៣០០០០ដុល្លា ខ្លួនបានប្រគល់អោយដើមចោទ រួចហើយ ។

៣.តាមឯកសារភស្តុតាងជាកំណត់ដៃទទួលប្រាក់ (ឯ.១/៧) របស់ដើមចោទ ឈ្មោះ [redacted] ហេងហួរ ឃើញមានការប្រគល់ទទួលប្រាក់នៅថ្ងៃទី ២០.២.២០០៩ ឈ្មោះ [redacted] វី បានទទួលប្រាក់ជាលើកទី១ ពីឈ្មោះ [redacted] ណុប ចំនួន ៥០០០ដុល្លាអាមេរិក ។ នៅថ្ងៃ ១១.៣.២០០៩ ឈ្មោះ [redacted] វី បានទទួលប្រាក់ជាលើកទី២ ចំនួន ៥០០០ដុល្លាអាមេរិក ។ នៅថ្ងៃ ២៥.៣.២០០៩ ឈ្មោះ [redacted] វី បានទទួលប្រាក់ជាលើកទី៣ ចំនួន ៥០០០ដុល្លាអាមេរិក ។ នៅថ្ងៃ ១២.៤.២០០៩ ឈ្មោះ [redacted] វី បានទទួលប្រាក់ជាលើកទី៤ ចំនួន ៥០០០ដុល្លាអាមេរិក សរុបទាំង ៤លើក ចំនួន ២០០០០ដុល្លាអាមេរិក ។ នៅក្នុងកំណត់ដៃរបស់ដើមចោទ ឃើញការប្រគល់ទទួលប្រាក់តែ ៤លើកប៉ុណ្ណោះ ។ ដើមចោទថា ចុងចម្លើយមិនបានប្រគល់ប្រាក់ជំហានទី៥ និងទី៦ សរុប ១០០០០ដុល្លាអាមេរិកទេ ។

៤.តាមកំណត់ហេតុ ចុះថ្ងៃ ២២ កក្កដា ២០០៩ នៅសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ ឈ្មោះ [redacted] ហេងហួរ បានឆ្លើយថា ឈ្មោះ [redacted] ណុប បានម៉ៅការអោយប្តីនាងខ្ញុំឈ្មោះ [redacted] វី សាងសង់ផ្ទះ ២ល្វែង តម្លៃ ៣០០០០ដុល្លា និងចាក់ប្លង់សេ តម្លៃ ៦០០០ដុល្លា ។ មកដល់ថ្ងៃ ២២ កក្កដា

១៦៧

Scanned with CamScanner

២០០៩ នាងខ្ញុំ និងប្តីទើបទទួលប្រាក់បាន ចំនួន ២៥០០០(ពីរម៉ឺនប្រាំពាន់) ដុល្លា លើថ្លៃម៉ៅការសង់ផ្ទះ ២ល្វែងខាងក្រោម និងទទួល ៤៩០០(បួនពាន់ប្រាំបួនរយ)ដុល្លា លើថ្លៃចាក់ប្លង់សេជាន់ទី១ សរុបនៅខ្វះនាងខ្ញុំ ៦១០០(ប្រាំមួយពាន់មួយរយ)ដុល្លា ។ ឃើញថា ដើមចោទទាមទារអោយឈ្មោះ [redacted] ណុប សង ១១០៩៥(មួយម៉ឺនមួយពាន់កៅសិបប្រាំ)ដុល្លានោះមិនត្រឹមត្រូវទេ ហើយកំណត់ដែនៃការប្រគល់ប្រាក់របស់ដើមចោទ ឈ្មោះ [redacted] ហេងហួរ មិនអាចយកជាការបានដែរ ។

៥.តាមកំណត់ហេតុ ចុះថ្ងៃ ២៣ កក្កដា ២០០៩ របស់ការិយាល័យសេដ្ឋកិច្ចសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ ឈ្មោះ [redacted] សុខណារី ប្រពន្ធរបស់ឈ្មោះ [redacted] ណុប បានឆ្លើយថា នាងខ្ញុំបានអោយឈ្មោះ [redacted] រី សាងសង់ផ្ទះ ២ល្វែង ជាន់ $E_0$ តម្លៃ ៣០០០០ដុល្លា និងអោយចាក់ប្លង់សេជាន់ $E_1$ តម្លៃ ៦០០០ដុល្លា ។ មកដល់ថ្ងៃ ២៣.៧.២០០៩ នេះ ឈ្មោះ [redacted] រី និងប្រពន្ធបានបើកប្រាក់អស់ចំនួន ៣៤៩២០ដុល្លាអាមេរិក (បីម៉ឺនបួនពាន់ប្រាំបួនរយម្ភៃ) នៅខ្វះតែ ១០៨០ដុល្លាទៀត ដោយធ្វើផ្ទះមិនទានហើយ ១០០% ។ ឃើញថា ចុងចម្លើយបានប្រគល់ប្រាក់ ថ្លៃម៉ៅការសាងសង់ផ្ទះ ២ល្វែង ជាន់ $E_0$ គ្រប់ចំនួន ៣០០០០ដុល្លា ឯប្រាក់នៅជំពាក់ គឺថ្លៃចាក់ប្លង់សេ ជាន់ $E_1$ តម្លៃ ៦០០០ដុល្លា ហើយបានប្រគល់អោយដើមចោទ ៤៩២០ដុល្លា ស៊ីសង្វាក់ទៅនឹងដើមចោទ ថាទទួលបាន ៤៩០០ដុល្លា ។ ដូចនេះ កំណត់ដែររបស់ចុងចម្លើយមានលក្ខណៈច្បាស់លាស់ អាចយកជាការបាន ។

៦.ក្នុងការម៉ៅការសាងសង់ផ្ទះល្វែងរបស់ដើមចោទ ឈ្មោះ [redacted] ហេងហួរ និងប្តីឈ្មោះ [redacted] រី ដោយមានការបង់ប្រាក់ ៦ជំហាន ពីចុងចម្លើយឈ្មោះ [redacted] ណុប និងប្រពន្ធឈ្មោះ [redacted] សុខណារី បើឈ្មោះ [redacted] ណុប ខកខាន មិនបំពេញកាតព្វកិច្ចបង់ប្រាក់តាមជំហានណាមួយនោះ ភាគីម៉ៅការ ឈ្មោះ [redacted] ហេងហួរ និងប្តីឈ្មោះ [redacted] រី ក៏មិនបំពេញកាតព្វកិច្ចសាងសង់អោយហើយគ្រប់ជំហានដែរ ហើយក៏គ្មានការសាងសង់ ចាក់ប្លង់សេបន្ថែមឡើយ ។ ដូចនេះ ចុងចម្លើយបានប្រគល់ប្រាក់ ១០០០០ដុល្លា ក្នុងជំហានទី៥ និងទី៦ រួចហើយ ប្រាក់ដែលចុងចម្លើយនៅជំពាក់ដើមចោទ តែ ៦០០០$ -៤៩២០$=១០៨០$ ។ គប្បីអោយចុងចម្លើយសងទៅដើមចោទ ។

៧.សាលក្រមរដ្ឋប្បវេណី លេខ ៧៤"ធ" ចុះថ្ងៃ ៤ ធ្នូ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវ លើកលែងតែ ចំនួនប្រាក់ដើម ដែលអោយចុងចម្លើយសងទៅដើមចោទ និងការប្រាក់ ត្រូវកែប្រែតាមការយល់ឃើញខាងលើ ។

## ហេតុដូចនេះ វិនិច្ឆ័យសេចក្តី

១.ព្រានចោលបណ្តឹងឧទ្ធរណ៍ លេខ ៦៦ ចុះថ្ងៃ ៦ មីនា ២០១៣ របស់ឈ្មោះ [redacted] ណុប គ្រង់អោយសងប្រាក់ ១០៨០ដុល្លាអាមេរិក ។

២.តម្កល់សាលក្រមរដ្ឋប្បវេណី លេខ ៧៤ "ធ" ចុះថ្ងៃ ៤ ធ្នូ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែ គ្រង់អោយចុងចម្លើយឈ្មោះ [redacted] ណុប សងប្រាក់ទៅដើមចោទ ចំនួន USD ១១០៩៥ ត្រូវកែប្រែទៅជាអោយសងចំនួន USD ១០៨០ និងសងការប្រាក់ ៥% លើប្រាក់ចំនួន USD ១០៨០ វិញ ។ ចំណុចផ្សេងទៀតតម្កល់ទុកជាបានការដដែល ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុកដើមចោទ ។

៤.សាលដីកានេះ បញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃ ២៦.៩.២០១៣ និងប្រកាសជា

Scanned with CamScanner

សាធារណៈ នៅថ្ងៃ ០១.១០.២០១៣ បើកសិទ្ធិប្តឹងសាទុក្ខរយៈពេល ១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| --- | --- | --- |

ហត្ថលេខា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី 17 ខែ [illegible] ឆ្នាំ២០១3.

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

១៦៥